**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * * * * * * * * *

# កិច្ចព្រមព្រៀង

**រវាង**

**ក្រុមហ៊ុន យ៉ុង ដេ វី ហ្គាមេន ភីធីវ៉ាយ អិលធីឌី**

**ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន**

នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២២ វេលាម៉ោង ០១ និង ៣០ នាទី រសៀល នៅក្នុងរោងចក្រ **យ៉ុង ដេ វី ហ្គាមេន ភីធីវ៉ាយ អិលធីឌី** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករ និយោជិក ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលឲសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិកចំនួន ១២៤ នាក់ (ស្រី ៩៦ នាក់) ក្នុងចំណោមកម្មករនិយោជិកសរុបចំនួន ១០៤៧ នាក់ ( ស្រី ៧៩៩ នាក់) រយះពេល ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០២២ ដល់ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២៣ ។ ហើយក្នុងកំឡុងពេលព្យួរកាងារនេះកម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧត្ថម្ភ ៣៦ ដុល្លាក្នុងមួយខែ៕

ប្រាក់ឧត្តម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនិងបើកជូនបងប្អូនកម្មករមុនថ្ងៃឈប់សំរាកមួយថ្ងៃ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ០២ និង ០០ នាទី រសៀលនាថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយនិងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងល្អ ។

ថ្ងៃសុក្រ ០២កើត ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២២

**តំណាងក្រុមហ៊ុន**

**ស្នាមមេដៃតំណាងកម្មករ និយោជិក**